# របាយការណ៍
# ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១៩
# និងទិសដៅការងារឆ្នាំ២០២០
# របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# និងពិធីប្រកាសជាផ្លូវការនៃការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូល
# អាស៊ី-អឺរ៉ុប លើកទី១៣ ឆ្នាំ២០២០
# ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០

- សូមគោរព សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
  នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សូមគោរព លោកជំទាវ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
  ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា
  តំណាងក្រសួង-ស្ថាប័ន អង្គទូតប្រចាំនៅកម្ពុជា
- ភ្ញៀវកិត្តិយស អង្គសន្និបាតទាំងមូល ជាទីមេត្រី!

ជាបឋម ខ្ញុំបាទសូមសម្តែងនូវការគោរព និងអំណរគុណដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជា-ណាចក្រកម្ពុជា ដែលបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងពិធីប្រកាសជាផ្លូវការនៃការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣ ឆ្នាំ២០២០ នាព្រឹកនេះ។ វត្តមានដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ** បញ្ជាក់សារជាថ្មីអំពីការយកចិត្តទុកដាក់បំផុតរបស់**សម្តេច**

ចំពោះការងារការបរទេស និងចំពោះមន្ត្រីការទូត មន្ត្រីរាជការ និងបុគ្គលិកក្រសួងការបរទេសទាំងមូល។

ខ្ញុំបាទក៏សូមអរគុណ និងស្វាគមន៍ផងដែរចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម លោកជំទាវ សមាជិក សមាជិការាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងតំណាងក្រសួង-ស្ថាប័ននានា អង្គទូតប្រចាំនៅកម្ពុជា និងសារព័ត៌មានដែលបានអញ្ជើញចូលរួមក្នុងពិធីដ៏សំខាន់នេះ។

ខ្ញុំបាទមានកិត្តិយស សូមគោរពជម្រាបជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ឆ្នាំនេះក្រសួងបានរៀបចំចាត់តាំងការប្រជុំចំនួនបីថ្ងៃ ដោយផ្តោតលើការផ្សព្វផ្សាយ ពិភាក្សាអំពីការងារបច្ចេកទេស ហិរញ្ញវត្ថុ ការងារការទូតសេដ្ឋកិច្ច ការរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣ និងពិគ្រោះពិភាក្សាគ្នារិះរកវិធានការ និងមធ្យោបាយដើម្បីបង្កើនប្រសិទ្ធភាព គុណភាពការងារ និងអនុវត្តឱ្យទទួលបានជោគជ័យនូវការងារធំៗទាំង៥ ដែល **សម្តេច** បានចង្អុលណែនាំកាលពីឆ្នាំទៅមិញ។ នៅក្នុងគោលដៅជម្រុញការងារការទូតសេដ្ឋកិច្ច ដើម្បីរួមចំណែកឱ្យកាន់តែសកម្មថែមទៀតដល់ការទាក់ទាញវិនិយោគពីបរទេស ពង្រីកទីផ្សារនាំចេញផលិតផលកម្ពុជា ទាក់ទាញទេសចរណ៍ និងលើកស្ទួយវប្បធម៌ជាតិលើឆាកអន្តរជាតិនោះ ក្រសួងបានអញ្ជើញវាគ្មិនមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីCDC និងពីក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើបទបង្ហាញអំពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ស្ថានភាពវិនិយោគបរទេស និងយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មរបស់កម្ពុជា។

អង្គសន្និបាតបានត្រួតពិនិត្យឡើងវិញនូវការងារទាំងឡាយក្នុងឆ្នាំ២០១៩ កន្លងទៅ ហើយកត់សម្គាល់ដោយការពេញចិត្តចំពោះសមិទ្ធផល និងការជឿនលឿនជាច្រើន ដែលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រេចបានក្នុងការបំពេញការងារជាអាទិភាពទាំង៥ នៅក្នុងកិច្ចការពារផលប្រយោជន៍គោលរបស់ជាតិ ការកសាងនិងពង្រីកទំនាក់ទំនងជាមួយប្រទេសនានានៅលើលោក ការជំរុញការងារការទូតសេដ្ឋកិច្ច និងវប្បធម៌ ការចូលរួមក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាព ការដោះស្រាយបញ្ហាប្រឈមនានានៅក្នុងពិភពលោក

និងការជម្រុញកំណែទំរង់ស្ថាប័ន ដើម្បីបង្កើនប្រសិទ្ធភាព និងគុណភាពការងារក្នុងក្រសួង។

- សម្តេចជាទីគោរព
- ឯកឧត្តម លោកជំទាវ
- អស់លោក លោកស្រី

ឆ្នាំ២០១៩ គឺជាឆ្នាំដែលយើងបានធ្វើការតស៊ូយ៉ាងសកម្ម និងស្វិតស្វាញនៅលើសមរភូមិការទូត និងសារជារណៈមតិ ដើម្បីការពារយុត្តិធម៌ ការពារឯករាជ្យ និងអធិបតេយ្យជាតិ ការពារសិទ្ធិស្វ័យសម្រេច រក្សាសន្តិភាព សន្តិសុខ ស្ថិរភាព សណ្តាប់ធ្នាប់ និងឯកភាពសង្គម។

ក្រសួងការបរទេសបានប្រកាន់ខ្ជាប់នូវគោលនយោបាយអព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ សន្តិសហវិជ្ជមាន មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងផងគ្នា និងគោរពគ្នាទៅវិញទៅមកនៅក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសទាំងអស់ លើពិភពលោក។

ពាក្យស្លោក «កំណែទម្រង់ខាងក្នុង បង្កើនមិត្តនៅក្រៅ ឈរលើស្មារតីឯករាជ្យជាតិ» ដែល**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនោះ ពិតជាសមស្របបំផុតទៅនឹងការងាររបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

មកដល់ពេលនេះ យើងបានភ្ជាប់ទំនាក់ទំនងការទូតជាមួយប្រទេសចំនួន ១៧៤ ហើយមានស្ថានតំណាងប្រចាំនៅបរទេសចំនួន៦៣។ យើងបានទិញអគាររៀបចំស្ថានទូតនៅទីក្រុងអង់ការ៉ា ចាប់ផ្តើមជួសជុលស្ថានទូតយើងនៅក្រុងសូហ្វីយ៉ា និងបែលក្រាដ ព្រមទាំងបើកស្ថានអគ្គកុងស៊ុលថ្មីនៅទីក្រុងហៃគូ។ ក្រសួងបានបង្កើតកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីចំនួន៨បន្ថែមទៀត ធ្វើឱ្យចំនួនសរុបកើនដល់ ៣៤។

ឆ្នាំទៅមិញ កម្ពុជាបានបំពេញតួនាទីជាអនុប្រធានមហាសន្និបាតអ.ស.ប. ជាសមាជិក ECOSOC និងអង្គការអន្តរជាតិមួយចំនួនទៀត បានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអន្តរជាតិសំខាន់ៗ និងទទួលមេដឹកនាំបរទេសជាច្រើន ចូលរួមវេទិកាធំៗ និងបំពេញទស្សនកិច្ចនៅប្រទេសជាមិត្ត ក្នុងនោះមានមិត្តចាស់នៅអឺរ៉ុបមួយចំនួនផង។

ស្ថានទូត ស្ថានអគ្គកុងស៊ុលយើងក៏បានយកចិត្តទុកដាក់ខ្ពស់ក្នុងការការពារផលប្រយោជន៍ពលរដ្ឋខ្មែរ ដែលរស់នៅ ធ្វើការ និងរៀនសូត្រនៅបរទេស ជួយដោះស្រាយបញ្ហាជូនពួកគាត់គ្រប់ពេលវេលា។

នៅលើការដ្ឋានកំណែទម្រង់ផ្ទៃក្នុងវិញ រយៈពេលជិត៤ឆ្នាំនេះ ក្រសួងបានធ្វើការកែទំរង់ច្រើនក្នុងនោះ លក្ខខណ្ឌការងារសំរាប់មន្ត្រីត្រូវបានកែលំអដោយមានរបបប្រាក់រង្វាន់សំរាប់មន្ត្រី និងបុគ្គលិកក្នុងក្រសួង ការតំឡើងប្រាក់ខែ ការផ្តល់របបធានារ៉ាប់រង និងការបង្កើនប្រាក់ឧបត្ថមសហព័ន្ធជូនមន្ត្រីការទូតនៅឯក្រៅប្រទេស ការបង្កើនកញ្ចប់ថវិកាចំណាយទូទៅសំរាប់ស្ថានតំណាងនៅបរទេសចំនួន១០% ការកែលំអកន្លែងធ្វើការ។ល។ កាន់តែសំខាន់ជាងគេ ការដាក់បញ្ចូលប្រព័ន្ធគុណូបធិបតេយ្យ ក្នុងការជ្រើសរើស តែងតាំង តំឡើងឋានៈ តួនាទីដល់មន្ត្រីយើង គឺបានរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យគុណភាព និងប្រសិទ្ធភាពការងារ ហើយជាពិសេសសមធម៌នៅក្នុងក្រសួងត្រូវបានធានា។ ដំណើរការដ៏សកម្មរបស់វិទ្យាស្ថានការទូត និងទំនាក់ទំនងអន្តរជាតិ ក៏បានជួយកសាងជួរអ្នកការទូតយើងឱ្យប្រកបដោយសមត្ថភាព និងកំរិតវិជ្ជាជីវៈកាន់តែខ្ពស់ ដើម្បីការពារផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ជាតិយើង។

- សម្តេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរព
- ឯកឧត្តម លោកជំទាវ
- អង្គសន្និបាតទាំងមូលជាទីមេត្រី

អង្គសន្និបាតបានធ្វើការពិនិត្យ វិភាគ វាយតម្លៃដោយភាពហ្មត់ចត់ និងប្រុងប្រយ័ត្ន បំផុតចំពោះសភាពការណ៍ពិភពលោក និងតំបន់ដែលកំពុងប្រែប្រួលយ៉ាងឆាប់រហ័ស ជ្រាលជ្រៅ ពិបាកប៉ាន់ស្មានបាន និងប្រកបដោយគ្រោះថ្នាក់បំផុត។ អង្គសន្និបាត មើលឃើញថាស្ថានភាពពិភពលោកប្រកបដោយភាពមិនច្បាស់លាស់ជាច្រើនដែល កើតចេញពីការបន្តប្រកួតប្រជែងយ៉ាងតានតឹងរវាងមហាអំណាចធំៗ ពីជម្លោះ ភូមិសាស្ត្រនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម បច្ចេកវិទ្យា សាសនា អធិបតេយ្យ ដែនដី និងពីការគំរាមកំហែងខាងសន្តិសុខប្រពៃណី និងមិនប្រពៃណីនានានោះ នឹងបន្តអូសបន្លាយក្នុងឆ្នាំ២០២០ និងបណ្តាឆ្នាំខាងមុខទៀត។

ដំណើរប្រែប្រួលទៅកាន់ប្រព័ន្ធពហុប៉ូលនឹងបន្តទៅមុខ ឯពហុភាគីនិយម នឹងបន្តរងសំពាធពីនយោបាយឯកតោនិយម និងគាំពារនិយម។

យ៉ាងណាក៏ដោយ ក៏ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រៀមខ្លួនជាស្រេចដើម្បីបន្តអនុវត្តគោលនយោបាយការបរទេស ដែលការពារ ផលប្រយោជន៍ជាតិផង និងចូលរួមវិភាគទានដល់សន្តិភាព ស្ថិរភាព និងវិបុលភាព ពិភពលោក ការលើកស្ទួយសណ្តាប់ធ្នាប់អន្តរជាតិ ដែលផ្អែកលើច្បាប់ និងការពង្រឹង ពហុភាគីនិយមក្នុងការដោះស្រាយបញ្ហាសកលទាំងឡាយផង។

នៅក្នុងទិសដៅពង្រីកមិត្តនៅខាងក្រៅ អង្គសន្និបាតក៏សុំលើកសំណើជូន រាជរដ្ឋាភិបាលពិចារណាអំពីលទ្ធភាពបើកស្ថានទូតថ្មីពីរកន្លែងទៀត គឺមួយនៅទ្វីប អាហ្វ្រិក ដែលសព្វថ្ងៃនេះមានស្ថានទូតតែមួយនៅទីក្រុងគែ ប្រទេសអេហ្ស៊ីប និងបើក ស្ថានទូតមួយទៀតនៅអាមេរិកឡាទីន ដែលយើងមិនទាន់មានសោះ។ ការបង្កើន ចំនួនស្ថានបេសកកម្មរបស់យើងនៅលើពិភពលោក ពិតជានឹងដាក់ទំងន់បន្ថែមនៅ លើស្មារបស់យើង។ ក្នុងស្មារតីនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្នុងខណៈដែលទូក របស់យើងរីកកាន់តែធំ រាជរដ្ឋាភិបាលនឹងផ្តល់ក្តោងកាន់តែធំដែរ ដើម្បីស្រូបខ្យល់រុញ ទូកនោះក្នុងល្បឿនមួយដែលស្របនឹងល្បឿននៃការវិវត្តន៍សភាពការណ៍ និងការផ្លាស់ ប្តូរនៃពិភពលោក។

ជាថ្មីម្តងទៀត ខ្ញុំបាទសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រ និងជ្រាលជ្រៅបំផុតជូនចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែងបានគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង និងបានដឹកនាំការងារការបរទេសប្រកបដោយសុភវិនិច្ឆ័យ និងគិតបណ្ឌិត សម្រាប់កម្ពុជាមួយឯករាជ្យ អធិបតេយ្យ សន្តិភាព សុខដុម អភិវឌ្ឍន៍ និងប្រកបដោយសេចក្តីថ្លៃថ្នូរ។

ខ្ញុំក៏សូមឆ្លៀតឱកាសនេះ អរគុណក្រសួង ស្ថាប័ន ស្ថានទូត ស្ថានបេសកកម្ម អង្គការអន្តរជាតិនានាដែលតែងផ្តល់កិច្ចសហប្រតិបត្តិការ និងការគាំទ្រដល់បេសកកម្មរបស់ក្រសួង។

ជាទីបញ្ចប់នេះ ខ្ញុំបាទសូមគោរពជូនពរ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយស សមាជិក សមាជិកា នៃអង្គសន្និបាតទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ និងទទួលបាននូវជ័យជំនះគ្រប់ភារកិច្ច។

ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំបាទសូមគោរពអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាថ្លែងសុន្ទរកថាបិទសន្និបាត និងប្រកាសជាផ្លូវការនូវការធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំ អាស៊ី–អឺរ៉ុប លើកទី១៣ នាចុងឆ្នាំនេះ។ សូមគោរពអញ្ជើញ **សម្តេច**។